រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ១៩ អនក្រ

ស្ដីពីការកែតម្រូវ និងបំពេញបន្ថែម អនុក្រឹត្យ

លេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា

ឆ្នាំ ១៩៩៣ របស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមក្រឹត្យ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ កញ្ញា ១៩៩៣
- យោងតាមក្រឹត្យ ចុះថ្ងៃទី ៣ សីហា ១៩៩៣ ស្ដីពីសញ្ញាឋានន្តរស័ក្តកងទ័ពជាតិកម្ពុជា
- តាមសំណើរបស់ ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ចុះថ្ងៃទី ០១ ខែមិនា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៣

## សំរេច

**មាត្រា ១ :** ត្រូវបានកែសំរួលអនុក្រឹត្យលេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៥ កក្កដា ឆ្នាំ ១៩៩៣ ភិបាលជាតិបណ្ដោះអាសន្នកម្ពុជា ស្ដីពីឯកសណ្ឋាន និងផ្លាកសញ្ញា នៃកងទ័ពជាតិកម្ពុជា ដូចខាងក្រោម ÷

១_ ក្នុងមាត្រា១ ចំណុច " ក " និងលេខ១ ឯកសណ្ឋានធំលេខ១ " អាវកុជីស "

- អាវកុជីស កត្រង់ ខោក្រមៅឆ្នូតក្រហម២ ម្ជុលធំពណ៌ខ្មៅសំរាប់ពាក់ក្នុងពិធីចូលក្នុងព្រះបរមរាជវាំង
- ខ្សែឥស្សរយសពណ៌មាស សំរាប់ពាក់លើអាវធំលេខ ១ និងលេខ ២ ស្មាឆ្វេង

២_ ក្នុងមាត្រា១ ចំណុច " ក " លេខ២ ឯកសណ្ឋានធំលេខ ២ សំរាប់ពាក់ក្នុងពិធីបុណ្យជាតិ អន្តរ

ជាតិ ក្រៅបរមរាជវាំង បំពេញបេសកកម្មក្រៅប្រទេស ទទួលភ្ញៀវជាតិ អន្តរជាតិ ។

៣- ត្រូវបានកែតម្រូវក្នុងមាត្រា២ ចំណុច " ក " ឯកសណ្ឋានកងនាវាចរខេមរភូមិន្ទ ឯកសណ្ឋានការងារសាហារីយ៉េន មួកកាស្កែត មួកបោរេ និងស្បែកជើងស្បែក កខ្មៅ ចងខ្សែ ពណ៌ស ទាំងអស់ ។

៤- ត្រូវបានបន្ថែមក្នុងមាត្រា ២ ចំណុច " ខ " ឯកសណ្ឋានកងអាកាសចរខេមរភូមិន្ទ

- ឯកសណ្ឋាន សាហារីយ៉េន និងការងារគ្រប់ប្រភេទ អាវពណ៌ខៀវ ខោពណ៌ខៀវ ពាក់មួកបោរេ ឬ មួកកាស្កែតពណ៌ខៀវ ម៉ូតដូចឯកសណ្ឋានទ័ពជើងគោក ។

- ឯកសណ្ឋានប្រយុទ្ធកងទ័ពអាកាសចរ មួកហ្សិកគី បេរ៉េ និងមួកហ្វាមធំពណ៌ខៀវ ឆ័ត្រយោងពណ៌ប៉ារ៉ា បេរ៉េពណ៌ក្រហម ។

៥- ត្រូវបានកែសំរួលក្នុងមាត្រា ៤ ចំណុច " គ " រូបព្រះសង្ហារ

- រូបព្រះសង្ហារនៅលើវ័ន្ត រូបព្រះសង្ហារសរសេរអក្សរថា " ព្រះចៅក្រុងកម្ពុជា "

៦- ត្រូវបានកែសំរួលក្នុងមាត្រា ៥ ចំណុច " ខ " ផ្លាកសញ្ញា នៃកងយោធពលខេមរភូមិន្ទ

- ផ្លាកសញ្ញាពាក់នៅលើដៃអាវស្តាំ ចុះពីថ្នេរស្មា ៥សម មានរាងមូលបន្ទាត់ផ្ចិត ៨សម ស្រទាប់ខាងក្រៅពណ៌ស ទំហំ ៣សម ខាងលើ ១ភាគ៤ ពណ៌ខៀវសរសេរអក្សរពណ៌សថា " ព្រះរាជាណាចក្រកម្ពុជា " កំពស់អក្សរ ៥មម នៅខាងក្រោម ១ភាគ៤ ពណ៌ខៀវសរសេរអក្សរពណ៌ស " ខ.ភ.ម " កំពស់អក្សរ ៥មម ចំកណ្តាលចំហរភាគ ២ ពណ៌ក្រហម ហើយមានប្រាសាទអង្គរវត្តកំពូល ៣ ។

- ផ្លាកសញ្ញារូបហនុមាន ធ្វើរាងជាមេដៃ ពាក់បន្តោងនៅឡេវហោប៉ៅអាវស្តាំ មានរាងមូលធ្វើពីពរសីឡែន ផ្នែកខាងលើមានម្កុដពណ៌មាស សំឡាដីមានរំយោលម្ខាង ៣ ផ្នែកកណ្តាលពណ៌ខៀវ ស៊ីផ្ទៃកណ្តាលមានរូបហនុមានកាន់ព្រះខ័ន្ធកំពុងសំដែងរិទ្ធិពណ៌ស្វាទុំ នៅរង្វង់ខាងក្រោមពណ៌ក្រហម ឆ្នូតជុំវិញពណ៌មាស នៅពីលើរង្វង់ផ្ទៃក្រហមសរសេរអក្សរកាត់"ខ.ភ.ម" ពណ៌ស ។

ខ្នាត ៖ - កំពស់រូបភាព ៦០មម ទទឹង ៤៥មម

- កំពស់ម្កុដ ២៧មម បាត ៣៨មម

- ផ្ទៃពណ៌ខៀវ ខ្នាតក្នុងកំពស់៣២មម ទទឹង៣០មម ហនុមានកំពស់២៤មម ទទឹង២៨មម

- វំយោលសង្វាងប្រវែង ១៦មម ទីពីរស្មើ ១៤មម ទីបីស្មើ ១២មម ពណ៌មាស
- វិរ័ណ្ណជើងពានខាងក្រោមមានរាងស្មែងក្របី បណ្ដោយប្រវែង ៣៨មម ទទឹងក្រហម ៦មម ពណ៌មាសព័ទ្ធជុំវិញ ១មម កំពស់អក្សរ ៤មម ។

**មាត្រា ២ :** រាល់ខ្លឹមសារណាដែលស្ថិតក្នុងអនុក្រឹត្យលេខ ០៤ អ.ន.ក្រ របស់រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា ដែលមិនបានកែសំរួលត្រូវស្ថិតនៅជាធរមាន និង ខ្លឹមសារណាដែលបានកែសំរួលតាមអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៤ :** អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថ និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ២៨ អនក្រ

### ស្ដីពីការតែងតាំងអនុព័ន្ធយោធា ប្រចាំនៅសហព័ន្ធរុស្ស៊ី

* * *

## រាជរដ្ឋាភិបាល កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា